


# អាហារូបករណ៍អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា២០១៩

## EDC Young Professionals Scholarship (EYPS)

ដើម្បីបន្តរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងអគ្គិសនីកម្ពុជាផ្ទាល់តាមរយៈការផ្តល់នូវបទពិសោធន៍ និងចំណេះដឹងពីឯកទេសដែលខ្លួនបានបញ្ចប់ការសិក្សា អគ្គិសនីកម្ពុជាផ្តល់អាហារូបករណ៍តាមរយៈកម្មវិធីអាហារូបករណ៍អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា **EDC Young Professionals Scholarship (EYPS)** ដល់និយោជិតកម្មករអគ្គិសនីកម្ពុជា ដែលមានសក្តានុពលទាំងផ្នែកបច្ចេកទេស ផ្នែកដឹកនាំ និងជំនាញផ្សេងៗទៀតឲ្យបានបន្តការសិក្សាថ្នាក់អនុបណ្ឌិត ចំនួន ០៤កន្លែង នៅក្រៅប្រទេសដែលជាសមាជិកអាស៊ាន។

### I. ឯកទេស និងចំនួនអាហារូបករណ៍

| | |
|---|---|
| - **High Voltage Relay Protection Coordination Design** | ចំនួន ០១កន្លែង |
| - **High Voltage Grid Substation Design** | ចំនួន ០១កន្លែង |
| - **Distribution System Planning** | ចំនួន ០១កន្លែង |
| - **Advanced Distribution Management System(ADMS)** | ចំនួន ០១កន្លែង |

### II. លក្ខខណ្ឌនៃការជ្រើសរើស

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ (ភ្ជាប់ព្រឹត្តិបត្រពិន្ទុ)
- ត្រូវមានអតីតភាពការងារនៅអគ្គិសនីកម្ពុជាយ៉ាងតិចចំនួន០៣ឆ្នាំ គិតត្រឹមថ្ងៃស្នើសុំអាហារូបករណ៍
- ត្រូវមានប្រវត្តិការងារ និងវិន័យល្អ ចេះធ្វើការជាក្រុម ចេះចែករំលែកបទពិសោធន៍ចំណេះដឹងជាមួយអ្នកដទៃ មានស្មារតីគោរពវិន័យចាត់តាំងរបស់អង្គភាព ជាអ្នកមានសក្តានុពលទាំងផ្នែកបច្ចេកទេស និងដឹកនាំសម្រាប់ទៅថ្ងៃអនាគត។
- ត្រូវទទួលបានលិខិតអនុញ្ញាតឲ្យសិក្សា (**Admission Letter**) ជាផ្លូវការ ពីមហាវិទ្យាល័យ ឬ សាកលវិទ្យាល័យ ដែលសាមីខ្លួនគ្រោងទៅសិក្សាជាមុន
- ត្រូវមានចំណេះដឹងភាសាអង់គ្លេសស្ទាត់ជំនាញ
- ត្រូវមានអាយុក្រោម៣៥ឆ្នាំ គិតត្រឹមថ្ងៃឈប់ទទួលពាក្យ

### III. ការផ្តល់អាទិភាព

- ចំពោះនិយោជិតកម្មករអគ្គិសនីកម្ពុជា ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌនៃការជ្រើសរើស ហើយបានដាក់ពាក្យស្នើសុំអាហារូបករណ៍មុនកាលបរិច្ឆេទកំណត់ និងសមស្របទៅតាមតម្រូវការជំនាញចាំបាច់របស់អគ្គិសនីកម្ពុជានឹងត្រូវបានផ្តល់អាទិភាព។
- លើកទឹកចិត្តចំពោះបេក្ខនារី និងបេក្ខជនមកពីបណ្តាខេត្ត ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នាគឺ ត្រូវបានផ្តល់អាទិភាព។
- លើកទឹកចិត្តទៅសិក្សានៅប្រទេសសិង្ហបុរី ដែលមានគុណភាពនៃការអប់រំខ្ពស់

**បេក្ខជនដែលមានចំណាប់អារម្មណ៍ចំពោះអាហារូបករណ៍ខាងលើ អាចមកទទួលពាក្យស្នើសុំនៅ ការិយាល័យមូលនិធិសង្គម និងអាហារូបករណ៍ នៅរៀងរាល់ម៉ោងធ្វើការ ឬ ចូលទៅកាន់ Website: http://www.edc.com.kh/edcscholarship.php**

**ផុតកំណត់ទទួលពាក្យ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩**

ការិយាល័យមូលនិធិសង្គម និងអាហារូបករណ៍
(ម៉ោងធ្វើការ ៧:៣០-១២:០០, ១៤:០០-១៧:៣០, ពី ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ)
អ៊ីម៉ែល៖ edcscholarship@gmail.com ទូរស័ព្ទលេខ៖ ០២៣ ៧២៣ ១៦៣
(អគារ B ជាន់ទី៣) អគ្គិសនីកម្ពុជា #២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ